## រឿងទី៧៖
## ការមានព្រះជន្មរស់ឡើងវិញ

**ខគម្ពីរ៖ យ៉ូហាន១១:២៥-២៦**

២៥ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ ២៦ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»

ក្រោយពេលព្រះយេស៊ូទ្រង់សុគតលើឈើឆ្កាងភ្លាម ពួកសាវ័ករបស់ទ្រង់ និងអ្នកដែលដើរតាមព្រះយេស៊ូទាំងអស់មានទុក្ខ សោកជាទម្ងន់។

ចំណែកឯមហាបូជាចារ្យ និងពួកមេដឹកនាំនៃក្រុមផារិស៊ី ពួកគេបានចាំពាក្យដែលព្រះយេស៊ូមានបន្ទូលពេលទ្រង់នៅមានព្រះជន្មថាទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ ដូច្នេះពួកគេបានបញ្ជាឱ្យពួកទាហានយកថ្មាំងថ្មដ៏ធ្ងន់មកបិទមាត់ផ្នូរហើយចាំយាមផ្នូររបស់ព្រះយេស៊ូទាំងយប់ទាំងថ្ងៃ។

នៅថ្ងៃទីបី ក្រោយព្រះយេស៊ូសុគត នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីជាម្ដាយយ៉ាកុបនិងសាឡូមេ ជាអ្នកដើរតាមព្រះយេស៊ូបានក្រោកពីព្រលឹមទៅផ្នូរដែលមានព្រះសពព្រះយេស៊ូ។ ពួកនាងបាននាំយកគ្រឿងក្រអូបទៅជាមួយ ដើម្បីអប់ព្រះសពព្រះយេស៊ូ។

ពេលទៅដល់ផ្នូរ ពួកនាងឃើញថ្មបានរមៀលចេញពីមាត់ផ្នូរ ឃើញថានៅក្នុងផ្នូរទទេស្អាត។ ពួកនាងរកព្រះសពព្រះយេស៊ូមិនឃើញទាល់តែសោះ។

ប៉ុន្តែ បែរជាឃើញមានទេវតាពាក់សកំពុងអង្គុយនៅកន្លែងដាក់ព្រះសពព្រះយេស៊ូទៅវិញ។

ទេវតានោះមានប្រសាសន៍ទៅពួកស្ត្រីនោះថា៖ «កុំភ័យស្រឡាំងកាំងធ្វើអ្វី! ដ្បិតយើងដឹងថាពួកនាងមករកព្រះយេស៊ូដែលបានឆ្កាងនៅលើឈើឆ្កាងនោះ។ ព្រះយេស៊ូទ្រង់មានព្រះជន្មរស់ឡើងវិញហើយ»។ ស្ត្រីទាំងនោះបាននាំដំណឹងដ៏អំណរនេះរត់ទៅប្រាប់គេឯង។ ពេលកំពុងរត់ទៅ ពួកនាងបានជួបនិងមនុស្សម្នាក់។ ហើយមនុស្សម្នាក់នោះ គឺជាព្រះយេស៊ូ។

ស្ត្រីទាំងនោះ មានចិត្តអរសប្បាយយ៉ាងខ្លាំង ក៏លុតជង្គង់ឱនក្រាបចាប់ជើងទ្រង់ហើយគោរពទ្រង់។

នៅល្ងាចថ្ងៃនោះ ពួកសាវ័កទាំងអស់ បានមកប្រជុំគ្នានៅក្នុងបន្ទប់លើដំបូលផ្ទះមួយនៅក្រុងយេរូសាឡឹម។

ពួកគេបានចាក់សោទ្វារយ៉ាងជាប់ ព្រោះខ្លាចពួកទាហានរ៉ូម៉ាំងមកចាប់ពួកគេ។ ពេលនោះ ព្រះយេស៊ូក៏លេចឡើងនៅចំពោះពួកសាវ័កទាំងអស់។

ពេលឃើញព្រះយេស៊ូភ្លាម ពួកសាវ័កទាំងអស់ភ័យតក់ស្លុត ញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានតែខ្មោចលង។ ពេលនោះព្រះយេស៊ូក៏មានបន្ទូលថា៖

«ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តដូច្នេះ? អ្នករាល់គ្នាបានឃើញខ្ញុំហើយ តើនៅសង្ស័យពីការមានព្រះជន្មរស់ឡើងវិញរបស់ខ្ញុំទៀតឬ? ចូរអ្នករាល់គ្នាស្ទាបមើល»។ ទីបំផុត ពួកសាវ័កទាំងអស់ ក៏ជឿថាព្រះយេស៊ូពិតជាមានព្រះជន្មរស់ពីសុគតពិតមែន។

ហើយពួកគេក៏បានលុតជង្គង់ថ្វាយបង្គំព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។



ព្រះយេស៊ូបានមានបន្ទូលទៅពួកសាវ័កទាំងអស់ថា៖ «ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»។

ព្រះយេស៊ូបានសន្យាថា នៅថ្ងៃចុងក្រោយនៃផែនដីនេះ ទ្រង់នឹងយាងមកម្ដងទៀត ដើម្បីជំនុំជំរះ។



**សកម្មភាពទី១** សូមគិតពីព្រះយេស៊ូដែលបានសម្រេចនូវការសង្គ្រោះ តាមរយៈការមានព្រះជន្មរស់ឡើងវិញ។





**សកម្មភាពទី២** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(យ៉ូហាន១១:២៥)

ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ
ខ្ញុំនឹងផ្តល់អោយគេមានជីវិត